**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
**សភាផ្នែករដ្ឋប្បវេណី**
សំណុំរឿង រដ្ឋប្បវេណី
លេខ:១០៣
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០០
**សាលដីកា**
លេខ:១៤
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០១

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០១ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម **ឌឹត មុន្នី** ជាប្រធាន
២-លោក **ប៉ែន ស៊ុន** ជាចៅក្រម
៣-លោក **ជីវ កេង** ជាចៅក្រម
៤-លោក **ស៊ិន ឌឹម** ជាចៅក្រមជាចៅក្រមរបាយការណ៍ ជំនួសលោក**វៀល មួន**
៥-លោក **យស់ សូខឿន** ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក **អ៊ូ សុផុន**

**តំណាងមហាអយ្យការ**

-លោក **ប៉ែន សាវឿន** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៤៥៨ ចុះថ្ងៃទី១៥ខែកក្កដា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣១១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍។

រវាងម្ចាស់បណ្តឹងសាទុក្ខឈួន សេង អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូពេទ្យ ទីលំនៅសព្វថ្ងៃក្រុម ១១ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ឈ្មោះឈួន សេង បានផ្ទេរសិទ្ធិឲ្យឈ្មោះតាន់ អេង ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះម៉ែន សម្បត្តិ តំណាងឲ្យឈ្មោះលី ប៊ុនឃៀង ជាចំណាង់ ឌុច អ៊ីម និងឈ្មោះលឹម គឹមស៊ា ទីលំនៅភូមិព្រែកមហាទេព ឃុំ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងសុំឲ្យអនុវត្តតាមកិច្ចសន្យាសម្រុះសម្រួល ចុះថ្ងៃទី២៧ -៦-១៩៩៧ ។

តាមពាក្យបណ្តឹងសាទុក្ខលេខ៣៥៩ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះតាន់ អេង បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៤៥៨ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១០៣ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៣-៤-៩៨ លោកម៉ែន សម្បត្តិ ,លី ប៊ុនឃៀង ,ឌុក អ៊ីម ជាចំណង់ និងឈ្មោះ លឹម គឹមស៊ារ បញ្ជាក់ថាៈ យើងប្តឹងសុំឲ្យចុងចម្លើយលោកឈួន សេង ឲ្យគោរព និងអនុវត្តកិច្ចសន្យាសម្រុះសម្រួលរបស់គណៈកម្មាធិការជំនាញចម្រុះខេត្តថ្ងៃទី ២៧-០៦-៩៧ ស្តីពីការ សាងសង់ និងប្តឹងសុំឲ្យចុងចម្លើយបន្ទាបដំបូលស័ង្កសីជញ្ជាំងហ្វីប្រូស៊ីម៉ង់ត៍ ចុះមកក្រោមពីព្រោះថាយើង បានធ្វើកិច្ចសន្យាព្រមព្រៀងជាមួយចុងចម្លើយនៅចំពោះមុខគណៈកម្មាធិការជំនាញចម្រុះខេត្តស្តីពីការសាងសង់នេះរួចហើយតែដល់ពេលសាងសង់ចុងចម្លើយពុំព្រមអនុវត្តតាមគោលការណ៍សាងសង់នេះឡើយ ដោយចុងចម្លើយរៀបជញ្ជាំងពីឥដ្ឋ បូកស៊ីម៉ង់ត៍ទៅវិញ ។

បានឃើញដីកាសម្រេចកិច្ចការប្រញ៉ាប់លេខ៧១៤ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៨ របស់តុលាការ ខេត្តបាត់ដំបង ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងសុំកិច្ចការប្រញ៉ាប់ ចុះថ្ងៃទី ១៦-៦-១៩៩៨ របស់ដើមចោទឈ្មោះ ម៉ែន សម្បត្តិ ប្តឹងសុំឲ្យចុងចម្លើយឈ្មោះ ឈួន សេង ផ្អាកសកម្មភាពការសាងសង់សំណង់តាមកំណត់ព្រំ នៃផ្ទះល្វែងទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ឲ្យចុងចម្លើយឈ្មោះ ឈួន សេង ជួសជុលបិទជញ្ជាំងត្រង់ចំណុចធ្លុះធ្លាយ បឹកន្លែងពីខាងក្រៅដោយឲ្យរក្សាសំណៅដែលបែកនៅដដែល តាមការឯកភាពរបស់គូភាគី ។

៣-ឲ្យចុងចម្លើយឈ្មោះ ឈួន សេង រក្សាទ្វារដែកទើបធ្វើថ្មីខាងក្នុងបន្ទប់នៅដដែល តាមការឯកភាពរបស់គូភាគី ។

៤-ហាមដាច់ខាតមិនឲ្យគូភាគីសាងសង់សំណង់ថ្មីផ្សេងពុះ លើទីតាំងដែលកំពុងមានទំនាស់ក្នុងសំណុំរឿងនៃអង្គសេចក្តី រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ២០០០៛ ដែលដើមចោទបានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ២០០៛ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៧ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ ។

៦-សេចក្តីសម្រេចនេះមានប្រសិទ្ធិភាពអនុវត្តភ្លាមពុះ បើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣២ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់តុលាការ ខេត្តបាត់ដំបង ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១-ក- ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៣-០៤-៩៨ និងសំណូមពរនាពេលសវនាការរបស់ដើមចោទឈ្មោះ ម៉ែន សម្បត្តិ, លី ប៊ុនឃៀង, ឌុក អ៊ីម, ជា ចំណង់ និងឈ្មោះ លឹម គឹមស៊ា ប្តឹងសុំឲ្យចុងចម្លើយ

ឈ្មោះ ឈួន សេង អនុវត្តតាមកិច្ចសន្យា សម្រុះសម្រួលចុះថ្ងៃទី ២៧-០៦-៩៧ និង ប្តឹងសុំឲ្យបន្ទាបដំបូលស័ង្កសី ជញ្ជាំងហ្វីប្រូស៊ីម៉ង់ត៍ ដែលមានទីតាំងទំនាស់ស្ថិតនៅ ក្រុម១១ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

ខ-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១២-១២-៩៦ របស់ដើមចោទឈ្មោះ ម៉ែន សម្បត្តិ, លី ប៊ុនឃៀង, ឌុក អ៊ីម, ជា ចំណង់ និងឈ្មោះ លឹម គឹមស៊ា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

គ-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ០៤-០២-៩៩ របស់ចុងចម្លើយឈ្មោះ ឈួន សេង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

ឃ-ទទួលសំណូមពររបស់ចុងចម្លើឈ្មោះ ឈួន សេង ប្តឹងសុំរក្សាទុកជញ្ជាំងទំនាស់ និង ប្តឹងសុំរក្សាទុកដំបូលជញ្ជាំងហ្វីប្រូស៊ីម៉ង់ត៍នៅភាពដដែល ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-ទទួលស្គាល់កំណត់ហេតុសម្រុះសម្រួលចុះថ្ងៃទី២៧-០៦-៩៧ របស់គណៈកម្មាធិការជំនាញចម្រុះខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៣-ឲ្យចុងចម្លើយឈ្មោះឈួន សេង គោរព និងអនុវត្តតាមកំណត់ហេតុសម្រុះសម្រួលចុះថ្ងៃទី ២៧-០៦-៩៧ របស់គណៈកម្មាធិការជំនាញចម្រុះខេត្តបាត់ដំបងគឺជញ្ជាំងទំនាស់ត្រូវធ្វើរនាំងពីចំរឹងដែកចាប់ពីជ្រុងទ្វារខាងលិចរបស់ឈ្មោះ ម៉ែន សម្បត្តិ ទៅដល់ជញ្ជាំងផ្ទះរបស់ចុងចម្លើយឈ្មោះ ឈួន សេង ដោយឲ្យចុងចម្លើយឈ្មោះ ឈួន សេង ចេញថវិការសាងសង់ដោយខ្លួនឯងតាមបច្ចេកទេស និង ការអនុញ្ញាតិឲ្យសាងសង់ពីសមត្ថកិច្ចជំនាញដូចមានចែងក្នុងអនុក្រឹត្យលេខ ៨៦អនក្របក ចុះថ្ងៃទី ១៩-១២-៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ចាប់ពីថ្ងៃដែលសាលក្រមចូលជាស្ថាពរ ។

៤-ឲ្យចុងចម្លើយឈ្មោះ ឈួន សេង បន្ទាបដំបូលជញ្ជាំងហ្វីប្រូស៊ីម៉ង់ត៍ ដែលមានទំនាស់ រឺ រៀបចំតាមការអនុញ្ញាតិរបស់សមត្ថកិច្ចជំនាញលើទំហំ, កំពស់, ប្រវែងទទឹង បណ្តោយ ដែលមានទីតាំងតាមគំនូសប្លង់បង្ហាញទីតាំងដំបូល និង ជញ្ជាំងទំនាស់នៅផ្ទះល្វែងជាន់ទី១ ក្រុម១១ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ចុះថ្ងៃទី២២-១២-៩៨ ដូចមានចែងក្នុងអនុក្រឹត្យលេខ ៨៦អនក្របក ចុះថ្ងៃទី ១៩-១២-៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ចាប់ពីថ្ងៃដែលសាលក្រមចូលជាស្ថាពរ ។

តាមមាត្រា ២, ១៤ នឹង ១៨ នៃអនុក្រឹត្យលេខ ៨៦អនក្របក ចុះថ្ងៃទី ១៩-១២-៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមមាត្រា ៣ និង ២៩ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រច ចុះថ្ងៃទី ២៨-១០-១៩៨៨ ។

៥-ឲ្យចុងចម្លើយឈ្មោះ ឈួន សេង បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ១៨០០៛ វង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ២០០៛ ចំណាយស៊ើបសួរ ៥០០០៛ សរុប ៧០០០៛ ។ ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន៧០០០៛ដែលដើមចោទបានបង់រួចហើយ កាលបើហួសឧទ្ទរណ៍ឲ្យចុងចម្លើយ សង

ប្រាក់នេះទៅដើមចោទវិញ ។ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៧ក្រ ចុះថ្ងៃទី០៨-០២-៩៣ ។

៦-សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងឧទ្ធរណ៍ ២ខែ គិតពីថ្ងៃទីប្រកាសសាលក្រមនេះ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៤ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ១៩៩៩ របស់ឈ្មោះម៉ែន សម្បត្តិ ដែលប្តឹងជំទាស់នឹងសាលក្រមលេខ ៣២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់តុលាការ ខេត្តបាត់ដំបងត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

បានឃើញសាលដីកាលេខ ៤៥៨ ចុះថ្ងៃទី១៥-០៦-៩៩ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ចុងចម្លើយចុះថ្ងៃទី ១៨-០៣-៩៩ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍របស់ដើមចោទចុះថ្ងៃទី០៧-០៤-៩៩ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៣-តម្កល់សាលក្រមលេខ ៣២ ចុះថ្ងៃទី ១០-០២-១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់។

៤-បង្គាប់ឲ្យឈ្មោះឈួន សេង សងប្រាក់ជម្ងឺចិត្ត និងការខាតបង់ចំនួន១.៥០០.០០០៛ (មួយលាន ប្រាំសែនរៀល) ទៅឲ្យដើមចោទ ។សំ ណូមពរលើសពីនេះបដិសេធចោល ។

៥-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលឈ្មោះម៉ែន សម្បត្តិ បានបង់ទុករួចហើយ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយក្នុងកិច្ច ប្រគល់ដីកាកោះ ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛។

កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់ឲ្យឈ្មោះឈួន សេង សងប្រាក់ ១៣.០០០៛ នេះទៅឲ្យឈ្មោះ ម៉ែនសម្បត្តិវិញ និង បង្គាប់ឲបង់ពន្ធសមាមាត្របន្ថែមមួយភាគរយលើទឹកប្រាក់ដែលតុលាការបានសម្រេចក្នុងចំណុចទី៤។ ប្រាក់ពន្ធនេះសម្រាប់ជាប្រយោជន៍ថវិការរដ្ឋ ៨០ភាគរយ និង ២០ ភាគរយជាប្រយោជន៏ក្រឡាបញ្ជីទទាំងប្រទេស។

៦-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៥៩ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះតាន់ អេង បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៤៥៨ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី២៧-០៣-២០០០ របស់ឈ្មោះឈួន សេង ។

បានឃើញសារណាចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះម៉ែន សម្បត្តិ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ សាលដីកាលេខ៤៥៨ ចុះថ្ងៃទី ១៥-០៧-៩៩ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ខ្លះ ខុសឆ្គងខ្លះ ។

បានស្តាប់ចម្លើយឈ្មោះតាន់អេង ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខដែលបានឆ្លើយនៅពេលសវនាការថា ៖ ខ្លួនពុំសុខចិត្តនឹងការទាមទារជំងឺចិត្តរបស់ឈ្មោះ ឈួន សេង ទេ។

ចំពោះបញ្ហាជញ្ជាំងឥដ្ឋទំនាស់នេះគឺខ្លួនបានសាងសង់នៅលើដីកម្មសិទ្ធិរបស់ខ្លួន ។

ក្រឡាបញ្ជីបានឡើយអានសារណារបស់ឈ្មោះ ម៉ែន សម្បត្តិ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការណ៍

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់លោកតាន់ អេង និងសារណារបស់លោកម៉ែន សម្បត្តិ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា៖បណ្តឹងសាទុក្ខលេខ៣៥៩ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៩៩ របស់លោកតាន់ អេង តំណាងឲ្យចុងចម្លើយធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាម មាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា៖ តំណាងចុងចម្លើយក៏ទទួលស្គាល់ដែលថាក្នុងការសាងសង់នេះចុងចម្លើយ ពុំបានអនុវត្តតាមកំណត់ហេតុសម្រុះសម្រួលចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ១៩៩៧ ហើយការលើកឡើង របស់តំណាងចុងចម្លើយក្នុងសារណារបស់ខ្លួនថាពេលសាងសង់ភាគីដើមចោទ ក៏បានឯកភាពហើយមិន តវ៉ានោះពុំមានភស្តុតាំងគួរឲ្យតុលាការជឿបានឡើយ ។

- យល់ឃើញថា៖ការដែលសាលាឧទ្ធរណ៍សម្រេចបន្ថែមដោយឲ្យចុងចម្លើយសងជម្ងឺចិត្តទៅ

ដើមចោទដោយសំអាងថាការប្តឹងឧទ្ធរណ៍របស់ចុងចម្លើយធ្វើឲ្យខាតបង់ផលប្រយោជន៍របស់ដើមចោទនោះ ជាការភ័ន្តច្រឡំ ពីព្រោះថា សំណើរសុំនេះជាសំណើរសុំថ្មីដែលតុលាការថ្នាក់ក្រោមពុំទាន់បានពិចារណា នៅឡើយម្យ៉ាងទៀតសិទ្ធិប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមជាសិទ្ធិដែលគូភាគីនៃរឿងក្តីមានតាមការកំណត់នៃច្បាប់ ។

- យល់ឃើញថា៖ លោកម៉ែនសម្បត្តិ បានធ្វើសារណាការពាររឿងក្តីរបស់លោកជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំរះកំបាំង ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា៖ សាលដីការដ្ឋប្បវេណីលេខ ៤៥៨ ចុះថ្ងៃទីទី ១៥ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ លើកលែងចំណុចស្តីពីជម្ងឺចិត្តដែលគប្បីបដិសេធចោល ។

**ហេតុដូចច្នេះ**

**ឧនិច្ឆ័យសេចក្តីចំពោះមុខលោកតាន់ អេង**

**កំបាំងមុខលោកម៉ែន សម្បត្តិ ចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៥៩ ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ១៩៩៩ របស់លោកតាន់ អេង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែគតិច្បាប់ត្រូវខ្លះខុ សខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៤៥៨ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងចំណុចទី២ ,៤ និងពន្ធសមាមាត្រដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១០៣ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីលើចំណុចទី ២ ទី៤ និងចំណុចស្តីពី ពន្ធសមាមាត្រនៃសាលដីការដ្ឋប្បវេណីលេខ៤៥៨ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោកឈួន សេង បានបង់រួចហើយគឺៈ

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីការកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០០១ ។